# កន្លង់រងគ្រោះ

(បទពាក្យ៨)

សាយ័ណ្ហសុរិយេទន់ទេរបាំងភ្នំ    ភពខ្មៅចូលហ៊ុំដណ្តប់លោកា
ចម្រៀងល្វើយៗហើរតាមវាតា    ដីក្រុងស្រស់ថ្លាភ្លើងភ្លឺចព្វែង។
កន្ទង់ហិចហោះបោះពួយកាន់ទី    បុប្ផាណាត្រីឆើតស្រស់ហួសថ្លែង
ភមរាត្រាច់ត្រេកព្រិលភ្នែកបែកផ្សែង    ប្រាថ្នាឥតក្រែងប្រជែងក្រេបជម។
លង់នឹងសម្ផស្សឆើតស្រស់ត្រកាល    នៃបនិត្យស្និទ្ធស្នាលប្រលែងបីបម
ប្រលោមក្រោមភ្លើងពណ៌ខៀវក្រហម    តន្ត្រីថ្នាក់ថ្នមអង្រួនដួងចិត្ត។
ភ្លូកភ្លឹកភ្លើនព្រហើនភ្លេចភ្លាំង    កាយឥតរនាំងរាំងរាបាំងបិទ
ដង្កូវក្នុងផ្កាខាំតោងជាប់ស្អិត    ពិសកាចស័ក្តិសិទ្ធឥតគ្រូព្យាបាល។
ស្រណោះភមរាឈឺផ្សាឥតល្ហែ    ចុករាល់ថ្ងៃខែគ្មានពេលធូរស្រាល
វិប្បដិសារីស្តាយវ័យត្រកាល    រងការផ្សាញ់ផ្សាលដោយពិសកំណាច។
ទោះដឹងថាខុសក៏ហួសទៅហើយ    ពុំអាចសះស្បើយរោគាបិសាច
រងទុក្ខវេទនារងាភ័យខ្លាច    មច្ចុរាជចិត្តកាចមកកាប់ប្រហារ។
យប់ថ្ងៃក្តុកក្តួលអួលណែនក្នុងចិត្ត    កំហុសនេះពិតព្រោះរឿងកាមា
ភក់ជ្រាំលោកិយចំណីតណ្ហា    ថ្ងោះធ្លោយកាយាធ្លាក់ជ្រោះទឹកភ្នែក។
សន្ទឹងសន្ធៅរីងរៃស្គមប្រាណ    ធ្វើអ្វីមិនបានមុខគួរសង្វេគ
អាណោចខ្លោចចិត្តអាណិតពន់ពេក    រូបកាយស្លាំងស្លេកដេកចាំមរណា។
លោកនេះទំនើបធើបចំរើនណាស់    ប៉ុន្តែនៅខ្វះថ្នាំជួយរក្សា
រោគកាចប្រល័យគួរអោយអនិច្ចា    ហេតុនេះហើយណាយើងគួរប្រយ័ត្ន។
កុំលង់សង្គមដែលជុំដោយកាម    កុំញៀនកុំញ៉ាមគួរចេះទប់ស្កាត់
ថែខ្លួនស្ងួនកាយអោយឆ្ងាយវិបត្តិ    នឹងអាចបំបាត់រោគកាមអប្រិយ។

(៣០ មករា ២០០២ )

ភិក្ខុ ស្វាត សាលឿម